**ចលនានិស្សិត**
ដើម្បីលទ្ធិប្រជាធិបតេយ្យ

**បេសកកម្ម ២០២១**
ឯករាជ្យជាតិ និង សន្តិភាពថ្លៃថ្នូរ
ទឹកដីព្រំដែន និង អន្តោប្រវេសន៍
សិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ
យុត្តិធម៌សង្គម និង នីតិរដ្ឋស្អាតស្អំ

**ក្រុមប្រឹក្សាភិបាល**
លោក ម៉ែន ណាត ប្រធាន
លោក គឹម សុខ អនុប្រធាន

**គណៈកម្មាធិការប្រតិបត្តិ**
លោក ទូច វិបុល ប្រធាន
លោក អ៊ាប សេង អនុប្រធាន

**STUDENT MOVEMENT FOR DEMOCRACY (SMD)**

**Mission 2021**
National Independence and Peace
Sovereignty and Immigration
Human Rights and Democracy
Social Justice and Rule of law

**Leadership**
Men Nath, Chairman of BoD
Kim Sok, Vice Chairman of BoD
Vibol Touch, President
Eab Seng, Vice President

*លេខ៖ ០០៨/២០២១ ច.ន.ប្រ.* រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១

# សេចក្តីថ្លែងការណ៍
# ថ្កោលទោសតុលាការក្រុងភ្នំពេញ
# ករណីកាត់ក្តីសកម្មជនបរិស្ថានទាំងអយុត្តិធម៌

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមថ្កោលទោសតុលាការក្រុងភ្នំពេញ ដែលបានកាត់ក្តីទាំងអយុត្តិធម៌ ទៅលើក្រុមសកម្មជនបរិស្ថាន៣រូប នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ មាន លោក **ថុន រដ្ឋា** កញ្ញា **ត្នួន កែវរស្មី** និងកញ្ញា **ឡុង គន្ធា** ក្រោមបទ«ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម» ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ចាត់ទុកថា ការកាត់ទោសនេះ គឺជាចេតនាបែបផែនការយុទ្ធសាស្ត្រនយោបាយទុច្ចរិត ក្នុងការបន្តសង្កត់សង្កិនជ្រុលហួសហេតុ លើសិទ្ធិសេរីភាពស្របច្បាប់ នៃប្រជាពលរដ្ឋម្ចាស់នគរ ដែលមានកាតព្វកិច្ចពេញលេញក្នុងការសម្រេច លើជោគវាសនាជាតិ។

- *មាត្រា៣៥ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជា* ចែងថា *«ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ»* ។

- *មាត្រា៤១ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជា* ចែងថា *«ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ»* ។

- *សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ១៩* ចែងថា *«មនុស្សគ្រប់រូប មានសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិ និងការសម្តែងមតិ ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពក្នុងការបញ្ចេញមតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា ដោយគ្មានព្រំដែន ទោះតាមរយៈ មធ្យោបាយសម្តែងមតិណាមួយក៏ដោយ»* ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ទាមទារដាច់ខាតឲ្យរដ្ឋាភិបាល និងតុលាការកម្ពុជា ទម្លាក់ចោលបទចោទ និងដោះលែងសកម្មជន លោក **ថុន រដ្ឋា** កញ្ញា **ត្នួន កែវរស្មី** និង កញ្ញា **ឡុង គន្ធា** ព្រមទាំងអ្នកឯទៀត ឲ្យមានសេរីភាពពេញលេញ ដើម្បីឲ្យពួកគាត់អាចអនុវត្តសិទ្ធិស្របច្បាប់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ស្នើរដ្ឋសភាកម្ពុជា ធ្វើវិសោធនកម្មលុបចោល «**បទញុះញង់ឲ្យប្រព្រឹត្តបទល្មើស**» ត្រង់ជំពូកទី៣ ផ្នែកទី៣ នៃក្រមព្រហ្មទណ្ឌ លើករណីនៃសេរីភាពបញ្ចេញមតិ ការសម្តែងមតិជាសាធារណៈ សេរីភាពនៃការស្រាវជ្រាវនិងផ្សព្វផ្សាយព័ត៌មាន និងគំនិតយោបល់ ទោះតាមមធ្យោបាយណាក៏ដោយ ដើម្បីបើកឱកាសឲ្យកាន់តែទូលាយដល់ប្រជាពលរដ្ឋទូទៅអាចចូលរួមចំណែកកែលម្អសង្គម ។ បើរដ្ឋាភិបាល និងរដ្ឋសភា នៅតែខំបង្រ្កួញលំហសិទ្ធិសេរីភាពប្រជាពលរដ្ឋ នោះអង្គការរដ្ឋនឹងក្លាយទៅជាឧបករណ៍អំណាចរបស់ក្រុមបុគ្គលប៉ុណ្ណោះ ។

**ប្រធានប្រតិបត្តិ**

**ទូច វិបុល**

2402 24th St SE
Washington, DC 20020
t: 743-999-2110
e: smd2khmer@gmail.com
@: cambodiademocracy.org